**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១១៣៦ ព.ណ.ភ.ស.ប

ថ្ងៃ ចន្ទ ១៣ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០២៣

# ជម្រាបមក

## លោក/លោកស្រីប្រធាន ក្រុមហ៊ុន យូ អិន ធី ហ្វូល សេល ខូ អិលធីឌី

**កម្មវត្ថុ៖** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលកាហ្វេកញ្ចប់ណេសកាហ្វេប្លេនអេនប្រ៊ូ កាហ្វេកំប៉ុងណេសកាហ្វេអេចប្រេសសូ កាហ្វេកំប៉ុងណេសកាហ្វេឡាតេ មីឡូម្សៅ និងមីឡូទឹកប្រអប់ក្រដាស ពាក់ម៉ាក MILO NESCAFÉ របស់ **ក្រុមហ៊ុន យូ អិន ធី ហ្វូល សេល ខូ អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង៖**
- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ **ក្រុមហ៊ុន យូ អិន ធី ហ្វូល សេល ខូ អិលធីឌី** ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Société des Produits Nestlé S.A. ចុះថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខបន្តរបស់ក្រុមហ៊ុន Nestle (Thai) Ltd. ចុះថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៥៦១៩៦/១៥ ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៥
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៥៨១៤០/១៦ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានក្រុមហ៊ុនថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់ សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលពាក់ម៉ាកខាងលើរបស់ **ក្រុមហ៊ុន យូ អិន ធី ហ្វូល សេល ខូ អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Société des Produits Nestlé S.A. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាព ត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Société des Produits Nestlé S.A. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល៩០(កៅសិប)ថ្ងៃគិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*__ចម្លងជូន:__*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469